សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការដាក់បាត្រលោក ឬក៏ការដាក់បាត្រព្រះសង្ឃ។
អញ្ចឹងនៅក្នុងប្រទេសកម្ពុជាគឺជាប្រទេសមួយដែលយើងកាន់ព្រះពុទ្ធសាសនា
ដូច្នេះហើយព្រះពុទ្ធសាសនាគឺមានព្រះសង្ឃ។ អញ្ចឹងនៅក្នុងប្រទេសកម្ពុជា
គឺយើងគោរពបូជាព្រះសង្ឃ បានន័យថាយើងចាត់ទុកព្រះសង្ឃ គឺជាមនុស្សដែលមានឋានៈខ្ពង់ខ្ពស់
យើងគោរពបូជា ហើយយើងតែងតែគោរពព្រះសង្ឃ ព្រោះថាព្រះសង្ឃគឺជាតំណាងនៃព្រះពុទ្ធ។
អញ្ចឹងជាទូទៅនៅពេលព្រឹក ព្រះសង្ឃតែងតែនិមន្តបិណ្ឌបាត
បិណ្ឌបាតគឺមានន័យថានិមន្តដើររកចង្ហាន់ ដែល
អ្នកដែលកាន់ព្រះពុទ្ធសាសនាតែងតែដាក់ចង្ហាន់ទៅដល់ព្រះសង្ឃ យើងហៅថាដាក់បាត្រ
ឬក៏ហៅថារាប់បាត្រ។ អញ្ចឹងពេលព្រឹកឡើងព្រះសង្ឃតែងតែនិមន្តមកផ្ទះប្រជាជន ដែលនៅក្នុងភូមិ
ឬក៏នៅក្នុងតាមផ្ទះនីមួយៗ ដើម្បីនិមន្តមកបិណ្ឌបាត អញ្ចឹងនរណាអ្នកណា
ឬក៏ប្រជាជនណាដែលគាត់ចង់ដាក់បាត្រព្រះសង្ឃ គាត់អាចដាំបាយ ឬក៏ធ្វើម្ហូប
ដើម្បីរង់ចាំទទួលព្រះសង្ឃ និងដាក់បាត្រឲ្យព្រះសង្ឃ ដើម្បីឧទ្ទិសទៅដល់បងប្អូន
ឬក៏ជីដូនជីតាដែលបានស្លាប់ទៅ។ អញ្ចឹងយើងដាក់បាត្រព្រះសង្ឃ គឺយើង
ដើម្បីយើងឧទ្ទិសទៅដល់បុព្វការីជន។

អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពនេះ គឺយើងមើលនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១
យើងឃើញមានស្ត្រីចំណាស់ម្នាក់ មើលទៅគាត់ប្រហែលជាអាយុ ៥០ ឆ្នាំ
ដែលស្ត្រីចំណាស់ម្នាក់នោះ គាត់កំពុងតែងើបពីគេង អញ្ចឹងយើងឃើញគាត់ពាក់អាវសដៃវែង
និងស្លៀកសំពត់ពណ៌ស អញ្ចឹងគាត់អាចស្លៀកជាសម្លៀកបំពាក់គេងបែបជាមនុស្សចាស់
ដោយសារតែគាត់មានអាយុ ៥០ ឆ្នាំ អញ្ចឹងបានន័យថាគាត់ចាស់។
អញ្ចឹងយើងឃើញគាត់ក្រោកពីគេង គឺគាត់នៅក្នុងបន្ទប់របស់គាត់
ដែលយើងឃើញគាត់អង្គុយលើគ្រែ ហើយនៅលើគ្រែរបស់គាត់គឺមានពូកមួយ អញ្ចឹងពូកគឺទន់
ដែលយើងគេងទៅគឺអត់សូវឈឺខ្នងទេ ប្រសិនបើយើងគេងលើពូកគឺអត់ធ្វើឲ្យឈឺខ្នងទេ
អញ្ចឹងគាត់កំពុងតែងើបពីគេង ក៏ប៉ុន្តែគាត់អត់ទាន់ក្រោកដើរទៅណាទេ គឺគាត់អង្គុយនៅលើគ្រែ
ហើយពត់ខ្លួនបន្តិច ដោយយើងឃើញគាត់លើកដៃទាំងពីរឡើង
ដែលដៃឆ្វេងរបស់គាត់លើកឡើងលើខ្ពស់ រីឯដៃស្តាំរបស់គាត់លូកទៅខាងស្តាំត្រង់។
អញ្ចឹងបានន័យថាគាត់កំពុងតែពត់ខ្លួននៅពេលដែលគាត់ក្រោកពីគេង។
អញ្ចឹងជាទូទៅនៅពេលដែលយើងក្រោកពីគេងយើងតែងតែពត់ខ្លួនដើម្បីឲ្យវា
យើងមានអារម្មណ៍ថាស្រស់ស្រាយ ឬក៏ស្រួលខ្លួនបន្តិច មុននឹងយើងធ្វើកិច្ចការអ្វីមួយបន្ទាប់ពីគេង។
ដែលយើងឃើញនៅខាងក្រោយខ្នងគាត់គឺមានភួយមួយ អញ្ចឹងជាទូទៅពេលគេង
យើងតែងតែគេងកើយលើខ្នើយ ហើយនិងដណ្តប់ភួយ អញ្ចឹងនៅពេលដែលយើងគេង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺភួយរបស់យើង យើងដាក់នៅខាងក្រោយ ឬក៏យើងវែកវាចេញ បានន័យថាយើងឈប់ដណ្ដប់ភួយ
អញ្ចឹងភួយគឺនៅលើគ្រែ។ ដែលយើងឃើញនៅលើជញ្ជាំងផ្ទះ ឬក៏ជញ្ជាំងបន្ទប់គាត់ គឺមានបង្អួចមួយ
អញ្ចឹងយើងឃើញបង្អួចនោះ នៅខាងក្រៅគឺមានភ្នំ ហើយមានព្រះអាទិត្យកំពុងតែរះ
អញ្ចឹងបានន័យថាវាជាពេលព្រឹក ឬក៏ពេលព្រលឹម អញ្ចឹងយើងឃើញព្រះអាទិត្យរះអត់ទាន់ផុតពីភ្នំទេ
បានន័យថាពេលព្រលឹម ដោយស្ត្រីចំណាស់ម្នាក់នោះ គាត់ក្រោកពីគេងនៅពេលព្រលឹម
ហើយគាត់អង្គុយពត់ខ្លួននៅលើគ្រែ។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញបន្ទាប់ពីគាត់ក្រោកពីគេងហើយ
បន្ទាប់ពីស្ត្រីចំណាស់ម្នាក់នោះគាត់ក្រោកពីគេងហើយ យើងឃើញគាត់មកនៅក្នុង
មកនៅក្នុងផ្ទះបាយ អញ្ចឹងគាត់មកផ្ទះបាយរបស់គាត់ដើម្បីចម្អិនម្ហូបឬក៏ដាំបាយ
ដែលយើងឃើញនៅក្នុងរូបភាពនេះ គាត់កំពុងតែធ្វើស៊ុប ឬក៏ធ្វើសម្ល
ដែលយើងឃើញនៅខាងមុខស្ត្រីចំណាស់ម្នាក់នោះគឺមានឆ្នាំងចំនួន ២
ដែលកំពុងតែនៅលើចង្ក្រាន។ អញ្ចឹងគាត់កំពុងតែធ្វើសម្ល ក៏ដូចជាដាំបាយ
ដែលយើងឃើញគាត់កំពុងតែកាន់វែក អញ្ចឹងដៃខាងឆ្វេងរបស់គាត់កំពុងតែកាន់វែកសម្ល
ហើយកូរទៅក្នុងឆ្នាំងសម្ល ដែលយើងឃើញគាត់កំពុងតែធ្វើសម្ល មានដូចជាប្រហែលជាសម្លការី
ឬក៏សម្លអ្វីផ្សេងដែលមានពណ៌ក្រហម។ អញ្ចឹងជាទូទៅសម្លការីគឺមានពណ៌ក្រហម
អញ្ចឹងប្រហែលជាគាត់ធ្វើសម្លការី ឬក៏ធ្វើសម្លអ្វីផ្សេងដើម្បីដាក់បាត្រលោក
ឬក៏ដើម្បីជាអាហារពេលព្រឹក ដែលយើងឃើញឆ្នាំងមួយទៀតគឺកំពុងតែបិទគ្រប មានគ្រប
អញ្ចឹងអាចគាត់កំពុងតែដាំបាយមួយឆ្នាំង ហើយនិងស្លសម្លមួយឆ្នាំង
ដែលយើងឃើញមានផ្សែងកំពុងតែហុយចេញពីឆ្នាំងទាំងពីរនោះ
បានន័យថាឆ្នាំងទាំងពីរគឺកំពុងតែក្ដៅ គឺគាត់កំពុងតែស្ល និងដាំបាយហើយក្ដៅ
គឺឆ្នាំងទាំងពីរគឺនៅលើចង្ក្រាន អញ្ចឹងយើងអត់អាចប៉ះផ្ទាល់ទៅឆ្នាំងបានទេ
ព្រោះថាប្រសិនបើយើងប៉ះផ្ទាល់វាអាចធ្វើឲ្យយើងរលាកបាន អញ្ចឹងយើងត្រូវប្រើវែក
ឬក៏ប្រើក្រណាត់ដើម្បីចាប់ឆ្នាំងនោះ ហើយដើម្បីកូរសម្លឲ្យបានសព្វគ្រឿង
ដើម្បីលាយគ្រឿងផ្សំឲ្យបានសព្វ គឺយើងត្រូវប្រើវែកដើម្បីកូរ គឺយើងអត់ប្រើដៃយើងទេ
ព្រោះវាអាចធ្វើឲ្យយើងរលាក។ អញ្ចឹងរូបភាពទី ២ នេះគឺស្ត្រីចំណាស់ម្នាក់នោះ
គាត់បានមកផ្ទះបាយរបស់គាត់ដើម្បីដាំស្ល បានន័យថាធ្វើម្ហូប និងដាំបាយ
ហើយគាត់កំពុងតែកូរសម្លរបស់គាត់នៅពេលដែលគាត់កំពុងតែចម្អិន។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ បន្ទាប់ពីគាត់ចម្អិនបាយម្ហូបឆ្អិនហើយ
យើងឃើញស្ត្រីចំណាស់ម្នាក់នោះក៏បានដួសបាយនិងម្ហូបរបស់គាត់ចូលទៅក្នុងថង់ចំនួនពីរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញនៅខាងមុខស្ត្រីចំណាស់ម្នាក់នោះ គឺយើងឃើញមានឆ្នាំងពីរ ដែលឆ្នាំងមួយគឺជាឆ្នាំងសម្ល អត់មានដៃទេ បានន័យថាឆ្នាំងសម្លគឺដៃខ្លី ចំណែកឯឆ្នាំងមួយទៀត គឺជាឆ្នាំងបាយ ដែលមានដៃកាន់វែង យើងឃើញមានដៃកាន់វែងនៅលើឆ្នាំងបាយ ហើយសម្លរបស់គាត់គឺពណ៌ក្រហម ចំណែកបាយគឺពណ៌ស។ អញ្ចឹងស្ត្រីចំណាស់ម្នាក់នោះ គាត់បានដួសបាយចេញពីឆ្នាំង ហើយដាក់ទៅក្នុងថង់ ឬក៏កញ្ចប់ចំនួនពីរ ដែលយើងឃើញកញ្ចប់នីមួយៗគឺមានបាយនិងមានម្ហូប អញ្ចឹងបានន័យថាគាត់កំពុងតែរៀបចំចង្ហាន់ ដើម្បីប្រគេនដល់ព្រះសង្ឃ ឬក៏ដើម្បីរាប់បាត្រដល់ព្រះសង្ឃ ដែលយើងឃើញគាត់បានខ្ចប់បាយជាពីរកញ្ចប់ ហើយកញ្ចប់នីមួយៗ គឺគាត់ដាក់ទាំងបាយទាំងសម្លចូលទៅតែម្តង។ អញ្ចឹងបានន័យថាគាត់ដាក់សម្លស្រូប ស្រូបលើបាយ លាយជាមួយបាយ ហើយខ្ចប់ចូលទៅក្នុងកញ្ចប់មួយ។ អញ្ចឹងគាត់ធ្វើបែបនេះគឺ ដើម្បីរៀបចំចង្ហាន់ទុកនៅពេលដែលព្រឹកឡើង គឺរាប់បាត្រ គឺរាប់បាត្រដល់ព្រះសង្ឃ។ អញ្ចឹងយើងឃើញដៃខាងឆ្វេងរបស់គាត់កំពុងតែរៀបចំដាក់នៅក្បែរកញ្ចប់បាយ ហើយដៃស្តាំគឺគាត់កាន់វែកបាយ គាត់កាន់វែកបាយ ហើយគាត់ដួសបាយចេញពីឆ្នាំង ដាក់ចូលទៅក្នុងកញ្ចប់មួយនោះដើម្បីរៀបចំ។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ យើងឃើញ បន្ទាប់ពីគាត់រៀបចំបាយចេញជាពីរកញ្ចប់ហើយ គាត់ក៏ចងកញ្ចប់នោះឲ្យបានស្អាត អញ្ចឹងគាត់បានចងមាត់ថង់ ឬក៏បិទកញ្ចប់នោះឲ្យបានស្អាត ហើយគាត់បានចេញមកខាងក្រៅផ្ទះ។ អញ្ចឹងរូបភាពទី ៤ នេះ យើងឃើញស្ត្រីម្នាក់នោះគាត់ពាក់អាវដៃវែងដដែល ស្លៀកសំពត់ពណ៌សដដែល ហើយគាត់ពាក់ស្បែកជើង អញ្ចឹងស្បែកជើងរបស់គាត់ គឺជាស្បែកជើងស៊ក យើងហៅថាស្បែកជើងស៊ក ហើយគាត់ពាក់ស្បែកជើងនោះចេញមកខាងក្រៅផ្ទះ ដោយយកកញ្ចប់បាយទាំងពីរមកដាក់លើតុមួយ អញ្ចឹងតុនោះគឺជាតុធម្មតា ឬក៏តុដែក ឬក៏តុអាចបត់បាន អញ្ចឹងនៅពេលដែលយើងត្រូវការលើកវាចេញក្រៅ យើងគ្រាន់តែយកវាចេញក្រៅហើយលាតវា យើងអាចលាតតុនោះទៅជារូបរាងតុមួយបាន ហើយនៅពេលដែលយើងចង់ទុកវិញ យើងបត់តុនោះទៅតាមរូបរាងរបស់វាវិញ អញ្ចឹងវាអាចមានរូបរាងស្តើង តុនោះគឺមានរូបរាងស្តើងនៅពេលដែលយើងបត់ទុក ប៉ុន្តែនៅពេលដែលយើងត្រូវការប្រើ យើងគ្រាន់តែលាតវាទៅគឺរូបរាងតុនឹងចេញជារាងតុ ដែលអាចឲ្យយើងប្រើប្រាស់បាន ដើម្បីសម្រាប់ដាក់អីវ៉ាន់ ឬក៏ដាក់សម្ភារៈផ្សេងៗ ហើយពេលខ្លះយើងអាចយកតុនោះមកញ៉ាំបាយផងដែរ។ អញ្ចឹង[...] ពេលខ្លះប្រជាជនកម្ពុជា គាត់ញ៉ាំបាយលើកន្ទេល គាត់ក្រាលកន្ទេល ហើយដួសបាយញ៉ាំលើកន្ទេល

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ចំណែកពេលខ្លះទៀតគ្រួសារខ្លះគឺគាត់ដាក់បាយលើតុ
អញ្ចឹងបានន័យថាគាត់ដួសបាយមកដាក់លើតុ ហើយអង្គុយលើកៅអីដើម្បីញ៉ាំបាយ
ប៉ុន្តែនៅក្នុងរូបភាពនេះគឺស្ត្រីចំណាស់ម្នាក់នោះ គាត់បានយកតុនោះ
ដើម្បីមកដាក់កញ្ចប់បាយរង់ចាំដាក់បាត្រដល់ព្រះសង្ឃ។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ បន្ទាប់ពីស្ត្រីចំណាស់ម្នាក់នោះគាត់បានរៀបចំចង្ហាន់
ឬក៏រៀបចំបាយរួចរាល់ហើយ គាត់ក៏បានចូលមកដាស់ចៅស្រីរបស់គាត់
អញ្ចឹងគាត់ចូលមកដាស់ក្មេងស្រីម្នាក់ដែលកំពុងគេង ដែលក្មេងស្រីម្នាក់នោះ
យើងមើលទៅអាយុគាត់ប្រហែលជា ៦ ឆ្នាំ អញ្ចឹងគាត់កំពុងតែគេងនៅក្នុងបន្ទប់គេងរបស់គាត់
អញ្ចឹងស្ត្រីចំណាស់ម្នាក់នោះគាត់បានមកដាស់ចៅស្រីរបស់គាត់ដើម្បីឲ្យក្រោក។
ជាទូទៅមនុស្សចាស់គាត់គេងលឿន បានន័យថាគាត់គេងឆាប់ភ្ញាក់។ គាត់សម្រាន្ត យើង
មនុស្សចាស់យើងប្រើពាក្យថាសម្រាន្ត ចំណែកឯក្មេងយើងហៅថាគេង ឬក៏ដេក
អញ្ចឹងមនុស្សចាស់គាត់គេង គាត់សម្រាន្តគឺគាត់ភ្ញាក់លឿន ហើយគាត់ភ្ញាក់នៅពេលព្រឹកព្រលឹម
ប៉ុន្តែក្មេងគឺគាត់អត់ចូលចិត្តភ្ញាក់លឿនទេ អញ្ចឹងគាត់គេងរហូតទាល់តែពេលព្រឹក
រហូតទាល់តែដល់យាយគាត់ដាស់។ អញ្ចឹងយើងឃើញ[...]ក្មេងស្រីម្នាក់នោះ គាត់កំពុងតែគេង
ដែលក្បាលរបស់គាត់កើយនៅលើខ្នើយ ហើយគាត់ដណ្តប់ភួយមួយ ដោយភួយនោះគឺពណ៌លឿង
អញ្ចឹងពេលនោះគឺជាពេលព្រឹកហើយ ដូច្នេះស្ត្រីចំណាស់ម្នាក់នោះ
គាត់បានទៅដាស់នាងឲ្យភ្ញាក់ឡើង អញ្ចឹងក្មេងស្រីតូចនោះគឺគាត់អត់ចង់ភ្ញាក់ទេ
ដោយសារតែគាត់ចូលចិត្តគេង ក្មេងគឺចូលចិត្តគេង ហើយគេចូលចិត្តឲ្យគេងឲ្យបានយូរ
គឺគេអត់ចង់ក្រោកទេនៅពេលដែលគេគេង អញ្ចឹងស្ត្រីចំណាស់ម្នាក់នោះដាស់ចៅស្រីរបស់គាត់
ដើម្បីឲ្យនាងក្រោកពីគេង ដើម្បីរៀបចំខ្លួន។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ បន្ទាប់ពីស្ត្រីចំណាស់ម្នាក់នោះ
គាត់បានដាស់ចៅស្រីគាត់ក្រោកហើយ អញ្ចឹងគាត់បាននាំចៅស្រីរបស់គាត់មកខាងក្រៅផ្ទះ
ដើម្បីអង្គុយរង់ចាំព្រះសង្ឃ។ ដែលយើងឃើញនៅក្នុងរូបភាពទី ៦ នេះ គឺពួកគេទាំងពីរនាក់
គឺកំពុងតែអង្គុយនៅលើកៅអីម្នាក់មួយ ដោយស្ត្រីចំណាស់ដែលជាយាយ
អញ្ចឹងចំពោះមនុស្សចាស់ហៅទៅកូនក្មេងយើងហៅថាចៅ
រីឯចៅត្រូវហៅមកមនុស្សចាស់វិញថាយាយ អញ្ចឹងពួកគេទាំងពីរនាក់គឺជាយាយនិងចៅ
ដោយស្ត្រីចំណាស់ជាយាយ និងក្មេងស្រីតូចម្នាក់នោះគឺជាចៅ។
ដោយយើងឃើញពួកគេទាំងពីរនាក់កំពុងតែអង្គុយនៅលើកៅអីនៅខាងមុខផ្ទះ
ដោយស្ត្រីចំណាស់គាត់អង្គុយលើកៅអី គាត់ដាក់ដៃរបស់គាត់ទាំងពីរនៅលើជង្គង់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់អង្គុយរង់ចាំដោយដាក់ដៃទាំងពីរនៅលើជង្គង់ រីឯក្មេងស្រីម្នាក់នោះគាត់ចងសក់ទីទុយ យើងឃើញសក់គាត់ចងទីទុយ ហើយគាត់ពាក់អាវដៃវែងពណ៌ស និងស្លៀកខោជើងវែងពណ៌ខ្មៅ ពាក់ស្បែកជើងប៉ាតា អញ្ចឹងពួកគេទាំងពីរនាក់កំពុងតែអង្គុយរង់ចាំដើម្បីដាក់បាត្រព្រះសង្ឃ ហើយនៅខាងមុខរបស់ពួកគេទាំងពីរនាក់គឺមានតុចំនួនមួយ អញ្ចឹងគឺមានតុមួយ ហើយដែលតុនោះ នៅលើតុគឺមានចង្ហាន់ឬក៏ម្ហូបអាហារចំនួនពីរកញ្ចប់ អញ្ចឹងម្ហូបអាហារចំនួនពីរកញ្ចប់នេះ គឺជាម្ហូបអាហារដែលស្ត្រីចំណាស់ម្នាក់នោះគាត់បានរៀបចំ ដើម្បីដាក់បាត្រដល់ព្រះសង្ឃ ឬក៏ដើម្បីរាប់បាត្រដល់ព្រះសង្ឃ។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញ បន្តិចក្រោយមក គឺមានព្រះសង្ឃមួយអង្គកំពុងតែនិមន្តមក អញ្ចឹងព្រះសង្ឃ គឺជាទូទៅគឺគាត់អត់មានសក់ទេ បានន័យថាយើងកោរសក់ចេញ ព្រះសង្ឃគឺកោរសក់ ហើយគាត់អត់ស្លៀកសម្លៀកបំពាក់ ឬក៏ខោអាវដូចយើងធម្មតាទេ គឺព្រះសង្ឃយើងហៅថាគ្រងស្បង់ចីវរ ឬក៏ស្បង់ចីពរ។ អញ្ចឹងព្រះសង្ឃគឺយើងហៅថាគ្រងស្បង់ចីពរ យើងអត់ហៅថាស្លៀកពាក់ទេ ដោយយើងឃើញនៅក្នុងរូបភាពនេះ ព្រះសង្ឃគាត់គ្រងស្បង់ចីពរពណ៌លឿង ហើយនៅដៃរបស់ព្រះសង្ឃ គឺកំពុងតែកាន់បាត្រមួយ ដែលបាត្រនោះពណ៌ស ហើយមានគម្របបាត្រពណ៌ខ្មៅ អញ្ចឹងជាទូទៅបាត្រគឺ បាត្រព្រះសង្ឃគឺសម្រាប់ដាក់ចង្ហាន់ ឬក៏ដាក់បាយ ដូច្នេះត្រូវតែមានគម្រប ព្រោះប្រសិនបើអត់គម្របទេ នៅពេលដែលព្រះសង្ឃដើរបិណ្ឌបាត ឬក៏ដើរបិណ្ឌចង្ហាន់នៅតាមផ្លូវ អាចដីហុយប្រឡាក់ចង្ហាន់បាន ដូច្នេះបាត្រត្រូវតែមានគម្របបិទឲ្យជិត បិទឲ្យស្អាត ហើយជាទូទៅព្រះសង្ឃអត់ពាក់ទ្រនាប់ជើងទេ ឬក៏អត់ពាក់ស្បែកជើងទេ ដោយសារតែព្រះសង្ឃគឺត្រូវតែដើរដោះស្បែកជើង អញ្ចឹងព្រះសង្ឃអត់អាចពាក់ ភាគច្រើនព្រះសង្ឃដើរបិណ្ឌបាត គឺអត់ពាក់ទ្រនាប់ជើង ឬក៏ស្បែកជើងនោះទេ ហើយយើងឃើញនៅខាងក្រោយព្រះសង្ឃគឺមានក្មេងប្រុសម្នាក់ ដែលក្មេងប្រុសម្នាក់នោះ អាយុគាត់ប្រហែលជា ១០ ឆ្នាំ ឬក៏ ១២ ឆ្នាំ អញ្ចឹងក្មេងប្រុសម្នាក់នោះ គឺយើងហៅថាកូនសិស្សលោក។ ដោយក្មេងប្រុសម្នាក់នោះគឺដើរតាមព្រះសង្ឃជានិច្ចនៅពេល[...] នៅពេលដែលព្រះសង្ឃដើរបិណ្ឌបាត ដោយក្មេង នៅចំហៀងក្មេងប្រុសនោះ គឺស្ពាយថង់យាមមួយ អញ្ចឹងគាត់ស្ពាយថង់យាមដើរ ដើរបិណ្ឌបាតជាមួយនឹងព្រះសង្ឃ ដោយកូនសិស្សលោកគឺជាអ្នកដែលរស់នៅជាមួយនឹងលោក ឬក៏អ្នកដែលរស់នៅនៅក្នុងវត្ត ហើយកូនសិស្សលោកគឺគាត់អត់ទៅផ្ទះទេ បានន័យថាគាត់ស្នាក់នៅនឹងវត្ត រៀននៅវត្ត ហើយជួយធ្វើការងារវត្ត និងហូបបាយនៅវត្តតែម្តង។ អញ្ចឹងគាត់ទុកវត្តដូចជាផ្ទះរបស់គាត់អញ្ចឹងដែរ ដោយគាត់ស្នាក់នៅជាមួយនឹងលោកតែម្ដង អញ្ចឹងនៅពេលដែលព្រះសង្ឃដើរបិណ្ឌបាត ឬក៏និមន្តទៅណាមកណា កូនសិស្សលោកតែងតែដើរទៅជាមួយ ដើម្បីជួយការងាររបស់ព្រះសង្ឃ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដូចជាស្ពាយយាម ឬក៏កាន់ថង់ កាន់បាត្រជាដើម ដែលជាក់ស្តែងយើងឃើញក្មេងប្រុសម្នាក់នេះ
គឺគាត់ពាក់អាវដៃខ្លី ខោជើងខ្លីពណ៌ស ហើយពាក់ស្បែកជើងផ្ទាត់ ហើយនៅដៃខាងឆ្វេងរបស់គាត់
គឺមានស្ពាយថង់យាម អញ្ចឹងកាបូបរបស់ព្រះសង្ឃយើងហៅថាថង់យាម។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ យើងឃើញថា
បន្ទាប់ពីព្រះសង្ឃនិមន្តដើរបិណ្ឌបាតតាមភូមិ ឬក៏តាមផ្ទះនីមួយៗរួចរាល់មក
បន្តិចក្រោយមកព្រះសង្ឃនោះក៏បានមកដល់ផ្ទះរបស់ស្ត្រីចំណាស់ម្នាក់នោះ។
អញ្ចឹងយើងឃើញនៅក្នុងរូបភាពទី ៨ នេះគឺស្ត្រីចំណាស់
ព្រះសង្ឃក៏បាននិមន្តមកដល់ផ្ទះរបស់ស្ត្រីចំណាស់នោះ បន្ទាប់មកព្រះសង្ឃក៏បានឈប់
ហើយរង់ចាំឲ្យស្ត្រីម្នាក់នោះគាត់ដាក់បាត្រ។ អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ
គឺព្រះសង្ឃគាត់ឈប់ ហើយក្មេងប្រុសដែលជាកូនសិស្សលោក គឺឈរនៅពីក្រោយព្រះសង្ឃ
ចំណែកឯស្ត្រីចំណាស់និងចៅស្រីរបស់គាត់កំពុងតែលុតជង្គង់នៅលើកម្រាលមួយ
អញ្ចឹងយើងឃើញស្ត្រីចំណាស់ដែលជាយាយគាត់លុតជង្គង់នៅលើកម្រាលមួយ
រីឯចៅស្រីរបស់គាត់លុតជង្គង់នៅលើកម្រាលមួយ ដែលកម្រាលរបស់ពួកគេគឺពណ៌លឿង
អញ្ចឹងពួកគាត់ទាំងពីរគឺកំពុងតែអង្គុយលុតជង្គង់ ដែល ក្នុងដៃរបស់ពួកគាត់ទាំងពីរ
គឺកាន់ថង់បាយម្នាក់មួយកញ្ចប់ៗ អញ្ចឹងពួកគេកំពុងតែអង្គុយលុតជង្គង់ចំពោះមុខព្រះសង្ឃ
ដោយការគោរព។ អញ្ចឹងយើង ជាទូទៅយើងគោរពព្រះសង្ឃដោយការលុតជង្គង់ និងការថ្វាយបង្គំ
ដូច្នេះហើយស្ត្រីចំណាស់និងចៅស្រីរបស់គាត់ត្រូវតែអង្គុយលុតជង្គង់
ម្យ៉ាងវិញទៀតពួកគេទាំងពីរនាក់ត្រូវតែដោះស្បែកជើងផងដែរ។
អញ្ចឹងនៅក្នុងការដាក់ចង្ហាន់ព្រះសង្ឃ ឬក៏ដាក់បាត្រព្រះសង្ឃ យើងត្រូវតែដោះស្បែកជើង
ព្រោះថាប្រសិនបើយើងពាក់ស្បែកជើង អាចធ្វើឲ្យយើងបាបបាន
អញ្ចឹងព្រះសង្ឃគឺដើរដោះស្បែកជើង ដូច្នេះយើងត្រូវតែដើរដោះស្បែកជើង
ហើយយើងអត់ត្រូវអង្គុយខ្ពស់ជាងព្រះសង្ឃនោះទេ ព្រោះព្រះសង្ឃតំណាងឲ្យព្រះពុទ្ធ អញ្ចឹងយើង
យើងអត់អាចអង្គុយខ្ពស់ជាងព្រះសង្ឃទេ ដូច្នេះយើងឃើញនៅក្នុងរូបភាពទី ៨ នេះ
គឺស្ត្រីចំណាស់ម្នាក់នោះនិងចៅស្រីរបស់គាត់ គឺកំពុងតែអង្គុយលុតជង្គង់នៅខាងមុខព្រះសង្ឃ។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា
បន្ទាប់ពីពួកគាត់អង្គុយលុតជង្គង់លើកម្រាលរួចរាល់ហើយ ពួកគាត់ទាំងពីរ ក្មេងស្រីម្នាក់នោះ និងចៅ
និងយាយរបស់នាង ដែលជាស្ត្រីចំណាស់ម្នាក់នោះ គាត់ក៏បានកាន់កញ្ចប់បាយ
និងលើកបាយឡើងដើម្បីបួងសួង។ អញ្ចឹងជាធម្មតាមុនពេលដែលយើងដាក់ចង្ហាន់
ឬក៏ដាក់បាត្រលោក ឬក៏ដាក់ចង្ហាន់ដល់ព្រះសង្ឃ យើងតែងតែបួងសួងសុំសេចក្តីសុខ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏សុំរកស៊ីមានបាន ហើយនិងឧទ្ទិសចំពោះបាយ
ឬក៏ម្ហូបនោះទៅដល់មនុស្សបងប្អូនសាច់ញាតិរបស់យើងដែលបានស្លាប់ទៅ។
ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៩ យើងឃើញស្ត្រីចំណាស់ម្នាក់នោះ
ជាមួយនឹងចៅស្រីរបស់គាត់ហ្នឹង គាត់កំពុងតែលើកបាយឡើង ដែលយើងឃើញគាត់កាន់បាយ
ដោយដៃទាំងពីររបស់គាត់ ដៃទាំងពីររបស់គាត់ គឺគាត់ទ្រកញ្ចប់បាយ
ហើយលើកឡើងកម្ពស់នឹងក្បាលរបស់គាត់ ហើយពួកគាត់ទាំងពីរនាក់កំពុងតែបិទភ្នែក
ដើម្បីបួងសួង។ អញ្ចឹងគាត់អាចសុំបួងសួងឲ្យមានសេចក្តីសុខ ឲ្យមានសុខភាពល្អ
ឲ្យមានការរកស៊ីមានបាន ក៏ដូចជាក្មេងស្រីម្នាក់នោះសុំបួងសួងឲ្យគាត់រៀនពូកែជាដើម។
អញ្ចឹងជាទូទៅការ ការដាក់បាត្រព្រះសង្ឃ មុននឹងយើងដាក់
យើងតែងតែបួងសួងនូវបំណងប្រាថ្នាផ្សេងៗដែលយើងចង់បាន។

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញព្រះសង្ឃក៏បានបើកបាត្រឡើង
អញ្ចឹងព្រះសង្ឃក៏បានបើកគម្របបាត្រ ដែលជាទូទៅបាត្រព្រះសង្ឃគឺតែងតែមានគម្រប
ដើម្បីការពារដីហុយ កុំឲ្យដីហុយចូលប្រឡាក់ចង្ហាន់ ឬក៏ប្រឡាក់មុខម្ហូប ឬក៏ម្ហូបអាហារ
ដែលព្រះសង្ឃមិនទាន់បិណ្ឌបាតបាន។
អញ្ចឹងដើម្បីឲ្យស្ត្រីចំណាស់និងចៅស្រីរបស់គាត់នោះដាក់ចង្ហាន់ឬក៏ដាក់បាត្រ
ព្រះសង្ឃត្រូវតែបើកគម្របបាត្រ ព្រោះថាការដាក់ចង្ហាន់គឺយើងតែងតែដាក់នៅក្នុងបាត្រជានិច្ច។
អញ្ចឹងយើងយកទៅដាក់ក្នុងបាត្ររបស់ព្រះសង្ឃ ដើម្បីប្រគេនដល់ព្រះសង្ឃ ដូច្នេះនៅក្នុងរូបភាពទី
១០ គឺព្រះសង្ឃកំពុងតែបើកគម្របបាត្រឡើង ដើម្បីឲ្យស្ត្រីចំណាស់និងចៅរបស់គាត់
អាចដាក់បាត្របាន។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញថា
បន្ទាប់ពីព្រះសង្ឃបើកបាត្ររួចរាល់ហើយ បើកគម្របបាត្រហើយ ស្ត្រីចំណាស់ម្នាក់នោះ
គាត់ក៏បានយកកញ្ចប់បាយទៅដាក់ចូលទៅក្នុងបាត្ររបស់ព្រះសង្ឃ
អញ្ចឹងបន្ទាប់ពីយើងបួងសួងរួចហើយ យើងកាន់កញ្ចប់បាយរបស់យើងបួងសួងរួចហើយ
យើងត្រូវយកចង្ហាន់របស់យើងទៅដាក់នៅក្នុងបាត្ររបស់ព្រះសង្ឃ ដើម្បីប្រគេនទៅដល់ព្រះសង្ឃ។
អញ្ចឹងជាទូទៅ មនុស្សស្រីអត់អាចប៉ះពាល់ព្រះសង្ឃបានទេ ដោយសារតែព្រះសង្ឃ
វិន័យរបស់ព្រះសង្ឃ គឺមិនឲ្យប៉ះពាល់មនុស្សស្រី ដូច្នេះយើងធ្វើយ៉ាងណា
ប្រសិនបើយើងជាមនុស្សស្រី យើងត្រូវតែប្រយ័ត្នមិនត្រូវប៉ះពាល់ព្រះសង្ឃនោះទេ
ព្រោះវាអាចធ្វើឲ្យយើងបាបបាន ហើយព្រះសង្ឃគឺខុសវិន័យសង្ឃផងដែរ
ដូច្នេះប្រសិនបើមនុស្សប្រុសគឺអត់អីទេ គឺប៉ះអត់អីទេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ប៉ុន្តែមនុស្សស្រីគឺយើងអត់ត្រូវប៉ះព្រះសង្ឃជាដាច់ខាត។ ដែលយើងឃើញស្ត្រីចំណាស់ម្នាក់នេះ
គឺគាត់គ្រាន់តែយកកញ្ចប់បាយដាក់ទៅក្នុងបាត្រព្រះសង្ឃ គឺគាត់អត់ឲ្យប៉ះព្រះសង្ឃនោះទេ។

បន្ទាប់មកទៀតរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថា បន្ទាប់ពីទទួលបានបាយ
កញ្ចប់បាយទាំងពីរពីស្ត្រីចំណាស់ម្នាក់នោះហើយ ព្រះសង្ឃក៏បានបិទគម្របបាត្រមកវិញ។
អញ្ចឹងបន្ទាប់ពីទទួលចង្ហាន់ ជាទូទៅព្រះសង្ឃតែងតែបិទគម្របបាត្រមកវិញជាមុនសិន
មុននឹងសូត្រធម៌ឲ្យពរ បានន័យថាព្រះសង្ឃបានទទួលចង្ហាន់រួចហើយ
បន្ទាប់មកគាត់ថែរក្សាចង្ហាន់នោះបានយ៉ាងល្អមិនឲ្យប្រឡាក់ គឺគាត់គ្របគម្របបាត្រទៅវិញ
ដើម្បីកុំឲ្យចង្ហាន់ប្រឡាក់ដី ឬក៏ប្រឡាក់ធូលីផ្សេងៗដែលហុយ។ អញ្ចឹងរូបភាពទី ១២
បន្ទាប់ពីទទួលចង្ហាន់រួច ព្រះសង្ឃនោះក៏បានបិទគម្របបាត្រមកវិញ។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា បន្ទាប់ពីស្ត្រីចំណាស់
និងចៅស្រីរបស់គាត់បានដាក់បាយចូលទៅក្នុងបាត្ររបស់ព្រះសង្ឃរួចរាល់ហើយ
ពួកគេទាំងពីរនាក់ក៏បានមកអង្គុយលុតជង្គង់នៅលើកម្រាលដដែលវិញ
អញ្ចឹងពួកគេនៅតែលុតជង្គង់ដដែល ព្រោះថាការដាក់ចង្ហាន់លោកគឺមិនទាន់ចប់នោះទេ
ដូច្នេះពួកគេត្រូវតែត្រលប់មកអង្គុយលុតជង្គង់នៅលើកម្រាលវិញ ហើយលើកដៃទាំងពីរសំពះឡើង
ដើម្បីបួងសួង អញ្ចឹងជាទូទៅរាល់ការដាក់បាត្រហើយ យើងត្រូវតែមកអង្គុយ ដើម្បីសំពះបួងសួង
និងទទួលពរពីព្រះសង្ឃ បានន័យថាព្រះសង្ឃនឹងសូត្រធម៌ដើម្បីឲ្យពរដល់យើង
ហើយនិងបួងសួងឲ្យយើង ដើម្បីឲ្យការធ្វើបុណ្យរបស់យើងនេះ គឺទទួលបានបុណ្យត្រលប់មកវិញ
ឬក៏ដើម្បីឧទ្ទិសទៅដល់អ្នកដែលបានស្លាប់ទៅ អ្នកដែលបានចែកឋានទៅដែលជាបងប្អូន
ឬក៏សាច់ញាតិរបស់យើង។ អញ្ចឹងព្រះសង្ឃតែងតែសូត្រធម៌ឲ្យពរ
ដើម្បីឲ្យសេចក្ដីសុខទៅដល់អ្នកដែលបានដាក់ចង្ហាន់
ហើយពួកយើងដែលបានដាក់ចង្ហាន់ទៅដល់ព្រះសង្ឃរួចហើយ យើងត្រូវតែលុតជង្គង់ដើម្បីសំពះ
ហើយសំពះដើម្បីសុំបួងសួង សុំពរពីព្រះសង្ឃ ដើម្បីសុំសេចក្ដីសុខ
ឬក៏ដើម្បីសម្រេចនូវបំណងប្រាថ្នាផ្សេងៗ។ អញ្ចឹងនៅក្នុងរូបភាពនេះ
យើងឃើញស្ត្រីចំណាស់និងចៅស្រីរបស់គាត់នៅតែលុតជង្គង់ ហើយសំពះដៃឡើង
លើកដៃសំពះឡើង សំពះព្រះសង្ឃ ហើយព្រះសង្ឃឈរនៅខាងមុខពួកគេទាំងពីរនាក់
ដោយកូនសិស្សរបស់ព្រះសង្ឃ ឬក៏កូនសិស្សលោកគឺឈរនៅខាងក្រោយ។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ គឺជារូបភាពរបស់ព្រះសង្ឃ
ដែលកំពុងតែសូត្រធម៌ឲ្យពរ។ អញ្ចឹងបានន័យថាបន្ទាប់ពីគាត់ទទួលបានចង្ហាន់ហើយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ព្រះសង្ឃត្រូវតែសូត្រធម៌ឲ្យពរដល់អ្នកដាក់ចង្ហាន់ទៅដល់ព្រះសង្ឃ ដើម្បីឧទ្ទិស ឬក៏ដើម្បីជូនពរដល់អ្នកដែលបានដាក់ចង្ហាន់ឲ្យបានសម្រេចនូវបំណងប្រាថ្នាផ្សេងៗរបស់គេដែលបានប៉ង។ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញព្រះសង្ឃកំពុងតែកាន់បាត្រ ដៃទាំងពីររបស់ព្រះសង្ឃកំពុងតែកាន់បាត្រ ហើយព្រះសង្ឃកំពុងតែសូត្រធម៌ ដើម្បីឲ្យពរទៅដល់ស្ត្រីចំណាស់ម្នាក់នោះ ជាមួយនឹងចៅស្រីរបស់គាត់ ឲ្យគាត់សម្រេចបំណងប្រាថ្នាផ្សេងៗទៅតាមការផ្សងរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១៥ រូបភាពទី ១៥ គឺយើងឃើញថា បន្ទាប់ពីព្រះសង្ឃបានសូត្រធម៌ឲ្យពរដល់ស្ត្រីចំណាស់និងចៅស្រីរបស់គាត់ហើយ អញ្ចឹងយើងឃើញព្រះសង្ឃក៏បានបែរមករកកូនសិស្សរបស់គាត់ ឬក៏កូនសិស្សលោកដែលឈរនៅខាងក្រោយ អញ្ចឹងកូនសិស្សលោកគាត់ឈរនៅខាងក្រោយព្រះសង្ឃជានិច្ច។ អញ្ចឹងបន្ទាប់ពីព្រះសង្ឃបានសូត្រធម៌រួចរាល់ហើយ គាត់ក៏បានបែរមករកកូនសិស្សរបស់គាត់វិញ អញ្ចឹងគាត់ គាត់បានបែរមករកកូនសិស្សលោក ហើយបើកគម្របបាត្រឡើង ដើម្បីឲ្យកូនសិស្សលោកដកចង្ហាន់ចេញពីបាត្រយកមកដាក់ក្នុងចង់យាម។ អញ្ចឹងដោយសារតែបាត្រនោះតូច បាត្រតូច ដូច្នេះអត់អាចដាក់ចង្ហាន់បានច្រើននោះទេ អញ្ចឹងរាល់ពេលដែលព្រះសង្ឃបានទទួលចង្ហាន់ពី[...] ពីស្ត្រីចំណាស់ម្នាក់នោះ ឬក៏ពីប្រជាជនរួចរាល់ហើយ ព្រះសង្ឃតែងតែយកចង្ហាន់នោះមកឲ្យកូនសិស្ស ដើម្បីយកចេញពីបាត្រដាក់ទៅក្នុងចង់យាមវិញ ដោយសារតែបាត្រតូចអត់អាចដាក់ចង្ហាន់បានច្រើនទេ ព្រោះវាពេញ ហើយអាចហៀរ និងធ្លាក់ចុះបាន ដូច្នេះគេត្រូវផ្ទេរចង្ហាន់ដាក់ចូលទៅក្នុងចង់យាម ដែលចង់យាមគឺជាកាបូបមួយរបស់ព្រះសង្ឃ គឺជាកាបូបធំមួយ បានន័យថាកាបូបធ្វើអំពីក្រណាត់ ហើយវាធំមួយដែលមានដៃយួរសម្រាប់ស្ពាយ អញ្ចឹងកាបូបនោះគឺធំ ដូច្នេះអាចដាក់ចង្ហាន់បានច្រើន។ អញ្ចឹងបន្ទាប់ពីព្រះសង្ឃគាត់ទទួលបានចង្ហាន់ពីប្រជាជន គាត់តែងតែយកចង្ហាន់ទាំងនោះមកឲ្យកូនសិស្ស ដើម្បីដាក់ទៅក្នុងចង់យាម។ អញ្ចឹងកូនសិស្សគាត់ស្ពាយចង់យាមដើរតាមពីក្រោយព្រះសង្ឃជានិច្ច ដែលនៅក្នុងចង់យាមនោះ គឺជាចង្ហាន់របស់ព្រះសង្ឃ។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញ បន្ទាប់ពីព្រះសង្ឃគាត់បានទទួលចង្ហាន់ពីស្ត្រីចំណាស់ម្នាក់នោះ រួមនឹងចៅស្រីរបស់គាត់ហើយ បន្ទាប់ពីគាត់ឲ្យពររួចរាល់ហើយ ព្រះសង្ឃក៏បានបន្តដំណើរទៅផ្ទះផ្សេងទៀត។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញព្រះសង្ឃក៏ ក៏និមន្តទៅដើររកបិណ្ឌបាតនៅផ្ទះផ្សេងទៀត នៅផ្ទះដែលក្បែរៗនោះ ដែលគេរង់ចាំដាក់ចង្ហាន់ព្រះសង្ឃ ឬក៏រង់ចាំដាក់បាត្រព្រះសង្ឃ ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺព្រះសង្ឃកំពុងតែនិមន្តនៅខាងមុខ កូនសិស្សនៅដើរតាមខាងក្រោយ។ អញ្ចឹងនៅពេលដែលព្រះសង្ឃដើរ យើងហៅថានិមន្ត យើងអត់ហៅថាដើរទេ ព្រោះថាយើងមានភាសាសម្រាប់ប្រើចំពោះព្រះសង្ឃ ដែលព្រះសង្ឃដើរ យើងហៅថានិមន្ត ព្រះសង្ឃហូប ឬក៏នៅពេលដែលព្រះសង្ឃញ៉ាំចំណីអាហារ យើងហៅថាឆាន់ យើងអត់និយាយថាញ៉ាំទេ គឺយើងប្រើពាក្យថាឆាន់។ អញ្ចឹងព្រះសង្ឃឆាន់ ព្រះសង្ឃនិមន្ត រីឯនៅពេលដែលព្រះសង្ឃគេង យើងហៅថាព្រះសង្ឃសិង អញ្ចឹងព្រះសង្ឃគឺមានភាសាផ្សេង យើងអត់ប្រើប្រាស់ភាសាដូចយើងធម្មតាទេ ដែលយើងឃើញថាពេលគេងយើងហៅថាសិង ពេលដើរយើងហៅថានិមន្ត ហើយនិងពេលញ៉ាំយើងហៅថាឆាន់ អញ្ចឹងយើងត្រូវប្រើប្រាស់ពាក្យពេចន៍ឲ្យបានត្រឹមត្រូវ នៅពេលដែលយើងនិយាយជាមួយនឹងព្រះសង្ឃ។ អញ្ចឹងនៅក្នុងរូបភាពទី ១៦ នេះ គឺព្រះសង្ឃកំពុងតែនិមន្តទៅរកផ្ទះផ្សេងទៀត ឬក៏និមន្តបិណ្ឌបាតទៅផ្ទះផ្សេងទៀត ដែលព្រះសង្ឃនិមន្តនៅខាងមុខ ចំណែកកូនសិស្សគឺគាត់ដើរនៅខាងក្រោយ។

បន្ទាប់មកទៀតរូបភាពទី ១៧ នៅក្នុងរូបភាពទី ១៧ យើងឃើញស្ត្រីចំណាស់ម្នាក់នោះ គាត់ក៏បានរៀបចំអីវ៉ាន់របស់គាត់ ដើម្បីត្រលប់ចូលក្នុងផ្ទះវិញ។ អញ្ចឹងស្ត្រីចំណាស់ម្នាក់នោះ គាត់ក៏បាន គាត់ក្រោកឈរឡើង ដោយគាត់ក្រោកឈរឡើង ហើយគាត់បានយកក្រណាត់ ឬក៏កម្រាលដែលគាត់លុតជង្គង់លើអម្បាញ់មិញមកបត់ ឬក៏មកមូរ ដើម្បីយកទៅទុក។ អញ្ចឹងយើងឃើញគាត់កំពុងតែឈរមូរកម្រាលដែលគាត់បានក្រាលលុតជង្គង់ ដើម្បីដាក់បាត្រព្រះសង្ឃអម្បាញ់មិញ ចំណែកឯក្មេងស្រីដែលជាចៅស្រីរបស់គាត់ គឺកំពុងតែអង្គុយ ហើយពាក់ស្បែកជើង ដោយសារតែស្បែកជើងនេះជាស្បែកជើងប៉ាតា ដូច្នេះវាពិបាកនឹងពាក់បន្តិច អញ្ចឹងក្មេងស្រីម្នាក់នោះ គាត់ត្រូវតែអង្គុយចុះ ហើយទាញស្បែកជើងរបស់គាត់មកពាក់ ដោយយើងឃើញគាត់អង្គុយ និងលើកជើងម្ខាងឡើង ជើងម្ខាងគាត់ដាក់នៅលើដី ជើងម្ខាងគាត់លើកឡើង ហើយយកស្បែកជើងមកពាក់នៅលើជើងដែលលើកឡើងលើនោះ។ ដោយយើងឃើញដៃទាំងពីររបស់ក្មេងស្រីម្នាក់នោះ គឺគាត់កាន់ស្បែកជើងដើម្បីពាក់ ហើយចំណែកឯស្បែកជើងរបស់ស្ត្រីចំណាស់ដែលជាយាយនោះ គឺគាត់ពាក់ស្បែកជើងស៊ក ដូច្នេះគឺងាយស្រួលក្នុងការពាក់ អត់ពិបាកទេ អញ្ចឹងក្មេងស្រីម្នាក់នោះគាត់ពិបាកពាក់ស្បែកជើង ដោយសារតែស្បែកជើងជាស្បែកជើងប៉ាតា។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៨ នៅក្នុងរូបភាពទី ១៨ យើងឃើញថា
បន្ទាប់ពីគាត់បានមូរកម្រាលឡើងរួចហើយ ហើយចៅស្រីរបស់គាត់
ក៏បានពាក់ស្បែកជើងរួចរាល់ហើយដែរ ដូច្នេះពួកគេទាំងពីរនាក់ក៏បានកាន់កម្រាលម្នាក់មួយៗ
ដោយយើងឃើញកម្រាលនីមួយៗគឺគាត់កៀបទៅនឹងក្លៀករបស់គាត់
អញ្ចឹងបានន័យថាកៀបទៅនឹងក្លៀកដែលនៅក្រោមស្មារបស់គាត់ ដែលយើងឃើញគាត់អត់កាន់ទេ
បានន័យថាគាត់ត្បៀតក្លៀក យើងហៅថាត្បៀតក្លៀក ដើម្បីយកកម្រាលនោះចូលទៅក្នុងផ្ទះ។
អញ្ចឹងពួកគេទាំងពីរនាក់ក៏បានដើរចូលទៅក្នុងផ្ទះ ហើយបំពេញការងារប្រចាំថ្ងៃរបស់ពួកគេវិញ
បន្ទាប់ពីពួកគេដាក់បាត្រព្រះសង្ឃរួច។ អញ្ចឹងយើងឃើញស្ត្រីចំណាស់ម្នាក់នោះ
គាត់ត្បៀតក្លៀកនូវកម្រាល គាត់យកកម្រាលមកត្បៀតក្លៀក ហើយដើរទៅខាង ដើរចូលទៅក្នុងផ្ទះ
ដែលចៅស្រីរបស់គាត់កំពុងតែដើរនៅខាងក្រោយ
អញ្ចឹងពួកគេទាំងពីរនាក់គឺមានអារម្មណ៍ថាស្រស់ស្រាយនិងសប្បាយរីករាយ
ដោយសារតែពួកគេបានដាក់បាត្រដល់ព្រះសង្ឃ ដែលជាចំណីអាហារ មានដូចជាបាយ
និងមានសម្លជាដើម ហើយពួកគេបានបួងសួងសុំនូវសេចក្ដីប្រាថ្នា
ឬក៏បំណងប្រាថ្នាផ្សេងៗឲ្យបានសម្រេច ព្រោះថាពួកគាត់ជាអ្នកកាន់ព្រះពុទ្ធសាសនា
ដូច្នេះពួកគាត់គោរពព្រះសង្ឃ និងពួកគាត់តែងតែចូលចិត្តធ្វើបុណ្យរាប់បាត្រជាមួយនឹងព្រះសង្ឃ
ហើយជាក់ស្ដែងគឺនៅក្នុងប្រទេសកម្ពុជាគឺជាប្រទេសដែលកាន់ព្រះពុទ្ធសាសនា
ដែលមានប្រជាជនជាង ៩០ ភាគរយគឺកាន់ព្រះពុទ្ធសាសនា និងគោរពព្រះសង្ឃ ដូច្នេះរៀងរាល់ថ្ងៃ
រៀងរាល់ពេលព្រឹក គឺតែងតែមានការដាក់ចង្ហាន់ ឬក៏ដាក់បាត្រដល់ព្រះសង្ឃ
ហើយចំណែកឯថ្ងៃសីល ដែលថ្ងៃសីល ជាថ្ងៃសីល គឺយើងតែងតែទៅវត្តដើម្បីស្ដាប់លោក
ស្ដាប់លោកសូត្រធម៌ ហើយនិងប្រគេនចង្ហាន់ដល់ព្រះសង្ឃនៅក្នុងវត្ត ចំណែកឯមិនមែនថ្ងៃសីល
គឺយើងរង់ចាំនៅក្នុងផ្ទះ ដើម្បីដាក់ចង្ហាន់ដល់ព្រះសង្ឃ ឬក៏ដាក់បាត្រដល់ព្រះសង្ឃ
ជាក់ស្ដែងដូចស្ត្រីចំណាស់ម្នាក់នេះ គឺគាត់ដាក់បាត្រនៅ ស្ត្រីចំណាស់ម្នាក់នេះ
គឺគាត់ដាក់បាត្រដល់ព្រះសង្ឃ នៅពេលដែលគាត់នៅផ្ទះ បានន័យថាគាត់អត់ទៅវត្តនោះទេ
គឺព្រះសង្ឃនិមន្តមកបិណ្ឌបាតនៅមុខផ្ទះរបស់គាត់តែម្ដង។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.